

ច្បាប់ CARE

# ច្បាប់ ស្តីពី ជំនួយសហគមន៍, ការស្តារឡើងវិញ និង ការផ្តល់សិទ្ធិអំណាច

## តួនាទីរបស់ជំនួយការនៅក្នុងច្បាប់ CARE

នៅក្នុងដំណើរការនីតិវិធី CARE អ្នកឆ្លើយតបម្នាក់ៗអាចជ្រើសរើសជំនួយការម្នាក់ (ត្រូវបានគេស្គាល់ផងដែរថាជា "ជំនួយការស្ម័គ្រចិត្ត")។ ជំនួយការគឺជាមនុស្សពេញវ័យដែលធ្វើឲ្យប្រាកដថាដំណើរការនីតិវិធី CARE បានធ្វើការឆ្លុះបញ្ចាំងពីសិទ្ធិ និងជម្រើសរបស់អ្នកឆ្លើយតប។ ជំនួយការធ្វើការជាដៃគូជាមួយសមាជិកផ្សេងទៀតនៃក្រុមការងារ CARE រួមមាន អ្នកឆ្លើយតប ទីប្រឹក្សា ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយាប្រចាំខោនធី និងចៅក្រម។

## ទិដ្ឋភាពទូទៅនៃតួនាទីអ្នកជួយគាំទ្រ

### តើតួនាទីអ្នកជួយគាំទ្រធ្វើអ្វីខ្លះ?

ជំនួយការគួរតែផ្តល់អំណាចដល់អ្នកឆ្លើយតបម្នាក់ៗ ដើម្បីបង្ហាញពីចំណង់ចំណូលចិត្តរបស់ពួកគេពេញមួយដំណើរការនីតិវិធី CARE។ នេះពាក់ព័ន្ធនឹងការគ្រប់គ្រងកិច្ចព្រមព្រៀង CARE ឬគម្រោង CARE ការបង្កើតផែនការបញ្ចប់ពីគម្រោង និងការបង្កើតការណែនាំជាមុនអំពីចិត្តសាស្ត្រ (ត្រូវបានគេស្គាល់ផងដែរថាជា PAD)(ក្រមសុខុមាលភាព និងស្ថាប័នរដ្ឋកាលីហ្វ័រញ៉ា (ក្រម W&I) §§ 5971( ), 5981)។ *

ប្រសិនបើអ្នកឆ្លើយតបមានអារម្មណ៍ធុញថប់ ឬច្របូកច្របល់ ពួកគេអាចស្នើសុំឱ្យជំនួយការពន្យល់ពីសមាសធាតុ និងគោលបំណងរបស់ CARE បាន។ ជំនួយការ និងអ្នកឆ្លើយតបអាចពិភាក្សាគ្នាតាមរយៈដំណើរការនីតិវិធីបាន។ ពួកគេក៏អាចបង្ហាញជាដ្យាក្រាម ឬជាសំណេរពីរបៀបដែលគម្រោងនេះដំណើរការបានផងដែរ។ ជំនួយការអាចកំណត់អត្តសញ្ញាណព័ត៌មាន ឬធនធានបន្ថែម ដែលអ្នកឆ្លើយតបត្រូវការ ដើម្បីធ្វើការជ្រើសរើសដោយខ្លួនឯងឱ្យបានល្អបំផុតក្នុងអំឡុងពេលដំណើរការនីតិវិធី CARE។

ជំនួយការមានកិច្ចការងារសំខាន់ និងប្រឈមណាស់។ ពួកគេជួយគាំទ្រអ្នកឆ្លើយតប ក្នុងនាមជាភាគីអព្យាក្រឹត ហើយធានាថាមតិយោបល់របស់អ្នកឆ្លើយតបនឹងត្រូវបានគោរព។

* អ្នកឆ្លើយតបអាចជ្រើសរើសបញ្ចូលសមាជិកផ្សេងទៀតឱ្យចូលរួមនៅក្នុងដំណើរការនីតិវិធី និងការជួយគាំទ្រក្រៅផ្លូវការផ្សេងៗទៀតបន្ថែម។

អ្នកជួយគាំទ្រ៖

1. ជួយអ្នកឆ្លើយតបឱ្យយល់ ធ្វើ និងទំនាក់ទំនងទៅលើការសម្រេចចិត្ត និងបង្ហាញពីចំណង់ចំណូលចិត្តពេញមួយដំណើរការនីតិវិធី CARE។

2. ផ្តល់ជូនអ្នកឆ្លើយតបនូវវិធីសាស្ត្រដែលអាចបត់បែនបាន និងឆ្លើយតបទៅតាមវប្បធម៌ ដើម្បីរក្សាសិទ្ធិអំណាចក្នុងការសម្រេចចិត្តលើជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ដោយអភិវឌ្ឍ និងថែរក្សាប្រព័ន្ធគាំទ្រដោយស្ម័គ្រចិត្ត។

3. ប្រើក្របខណ្ឌនៃការសម្រេចចិត្តដែលមានការជួយគាំទ្រ (SDM) ដើម្បីបង្កើនសមត្ថភាពរបស់អ្នកឆ្លើយតបក្នុងការសម្រេចចិត្តដោយខ្លួនរបស់ពួកគេផ្ទាល់។ ការធ្វើបែបនេះអាចទប់ស្កាត់ដល់ជម្រើសការពារដែលមានការរឹតត្បិតខ្លាំង ដូចជាការអភិរក្សជាដើម។

**សម្រាប់ព័ត៌មានបន្ថែមអំពីតួនាទី ទំនួលខុសត្រូវ និងការបណ្តុះបណ្តាលផ្សេងៗ សូមមើល ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត។**

DHCS CALIFORNIA DEPARTMENT OF HEALTH CARE SERVICES

# តើអ្នកណាជាជំនួយការ?

ជំនួយការ គឺជាមនុស្សពេញវ័យដែលត្រូវបានជ្រើសរើស (ឬអនុម័ត) ដោយអ្នកឆ្លើយតប ហើយគឺជាបុគ្គលដែលពួកគេទុកចិត្ត។ ជំនួយការ ត្រូវចំណាយពេលវេលាដើម្បីចូលរួមក្នុងអង្គសវនាការ និងការណាត់ជួបផ្សេងៗរបស់គម្រោង CARE (តាមដែលអ្នកឆ្លើយតបពេញចិត្តឱ្យចូលរួម)។ ជំនួយការអាចជា៖

- មិត្តភក្តិ។
- សមាជិកគ្រួសារ។
- អ្នកដឹកនាំផ្នែកសាសនា។
- អ្នកបណ្តុះបណ្តាល។
- បុគ្គលដែលមានបទពិសោធន៍ផ្នែកសុខភាពផ្លូវចិត្ត និង/ឬបញ្ហាប្រើប្រាស់សារធាតុញៀន។
- បុគ្គលិកភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយាប្រចាំខោនធី។
- អ្នកផ្តល់សេវាសង្គម។
- អ្នកជួយគាំទ្រផ្សេងទៀត។

ចំណាំ៖ បច្ចុប្បន្ននេះ មិនទាន់មានការបែងចែកថវិកាសម្រាប់តួនាទីអ្នកជួយគាំទ្រទេ។

## តើអ្វីខ្លះជាគោលការណ៍ប្រតិបត្តិការសំខាន់ៗនៃតួនាទីរបស់ជំនួយការ?

### 1. ការសម្រេចចិត្តដោយមានការជួយគាំទ្រ (SDM)

ការសម្រេចចិត្តដោយមានការជួយគាំទ្រ (SDM) គឺជាគោលការណ៍ដ៏សំខាន់នៃច្បាប់ CARE។ SDM ជួយដល់ជនពិការឱ្យរក្សាសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ ជាមួយនឹងសេវាកម្ម និងការជួយគាំទ្រដ៏ត្រឹមត្រូវ។ នៅក្នុងក្របខ័ណ្ឌ SDM បុគ្គលដែលគួរឱ្យទុកចិត្ត (ឬក្រុមមនុស្ស) ជួយបុគ្គលនោះឱ្យធ្វើការសម្រេចចិត្តដោយផ្ទាល់ខ្លួនរបស់ពួកគេ។ បុគ្គលដែលទុកចិត្តនោះនឹងមិនធ្វើការសម្រេចចិត្តជំនួសឱ្យអ្នកឆ្លើយតបឡើយ។ អ្នកឆ្លើយតប ត្រូវតែធ្វើការសម្រេចចិត្តចុងក្រោយ។

ដោយប្រើក្របខ័ណ្ឌ SDM ជំនួយការស្ម័គ្រចិត្តប្តេជ្ញាចូលរួមជាមួយក្រុមការងារច្បាប់ CARE របស់អ្នកឆ្លើយតបដោយសុឆន្ទៈ។ ជំនួយការម្នាក់ៗជួយអ្នកឆ្លើយតបឱ្យយល់ និងតំណាងឱ្យចំណង់ចំណូលចិត្ត និងការសម្រេចចិត្តរបស់ពួកគេ។ ការជួយគាំទ្រនេះកើតឡើងពេញមួយដំណើរការនីតិវិធី CARE។

### 2. មិនត្រូវមានការលំអៀងផ្ទាល់ខ្លួនឡើយ

ជំនួយការត្រូវតែតស៊ូមតិដោយចេតនាសម្រាប់បំណងប្រាថ្នា និងចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតប ទោះបីជាបំណងប្រាថ្នា និងចំណង់ចំណូលចិត្តទាំងនោះខុសពីខ្លួនក៏ដោយ។

### 3. ការថែទាំរបួសតាមបទដ្ឋានបច្ចេកទេស

អ្នកឆ្លើយតបជាច្រើនបានទទួលរងរបួស។ ការរងរបួសអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងរាងកាយរបស់ពួកគេ។ ការថែទាំរបួសតាមបទដ្ឋានបច្ចេកទេស មានន័យថាប្រតិបត្តិការប្រកបដោយការគោរព ជាប់ជាប្រចាំ និងអាចទុកចិត្តបាន។

វាអាចកាត់បន្ថយការប៉ះទង្គិចដល់ផ្លូវចិត្ត និងអាកប្បកិរិយាដែលពាក់ព័ន្ធនានាដល់អ្នកឆ្លើយតប។ ប្រតិបត្តិការក្នុងលក្ខណៈនៃការថែទាំតាមបទដ្ឋានបច្ចេកទេស គឺបានជួយដល់អ្នកឆ្លើយតប។ វានៅតែអាចរក្សាទំនុកចិត្តចំពោះជំនួយការបាន។ វាអាចបង្កើនការចូលរួមនៅក្នុងសេវាកម្មជួយគាំទ្រ។

### 4. ការសម្ងាត់

ជំនួយការ អាចចូលរួមក្នុងកិច្ចប្រជុំ ដំណើរការនីតិវិធី ឬការទំនាក់ទំនងណាមួយដែលទាក់ទងនឹងដំណើរការនីតិវិធី CARE។ ការចូលរួមរបស់ជំនួយការនេះមិនធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់ ឬចាត់ទុកជាមោឃៈនូវឯកសិទ្ធិនៃព័ត៌មានដែលបានពិភាក្សានោះទេ។ ជំនួយការត្រូវតែគោរពឯកជនភាពរបស់អ្នកឆ្លើយតប និងរក្សាព័ត៌មានទាំងអស់ជាការសម្ងាត់។ ជំនួយការមិនអាចធ្វើសកម្មភាពដោយឯករាជ្យ ឬចែករំលែកព័ត៌មានអំពីដំណើរការនីតិវិធី CARE ជាមួយអ្នកដទៃក្រៅពីអ្នកឆ្លើយតបឡើយ។ លើសពីនេះទៀត ជំនួយការមិនអាចត្រូវបានគេកោះហៅ ឬហៅឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងអ្នកឆ្លើយតបនៅក្នុងដំណើរការនីតិវិធីណាមួយដែលទាក់ទងនឹងច្បាប់ CARE នោះទេ។

## តើជំនួយការត្រូវបានជ្រើសរើសដោយរបៀបណា?

ទីប្រឹក្សារបស់អ្នកឆ្លើយតបនឹងប្រាប់អ្នកឆ្លើយតបអំពីជម្រើសក្នុងការជ្រើសរើសជំនួយការ។ ប្រសិនបើអាចធ្វើទៅបាន រឿងនេះគួរតែធ្វើនៅមុនថ្ងៃអង្គសវនាការដំបូងនៅក្នុងញត្តិ CARE ដូច្នេះ ជំនួយការ អាចជួយអ្នកឆ្លើយតបឱ្យយល់ពីញត្តិ និងចូលរួមក្នុងអង្គសវនាការ (ប្រសិនបើអ្នកឆ្លើយតបជ្រើសរើសយក)។

ពួកគេអាចឱ្យទីប្រឹក្សារបស់ពួកគេស្នើសុំឱ្យតុលាការរកជំនួយការស្ម័គ្រចិត្តម្នាក់បាន។ អ្នកឆ្លើយតបត្រូវតែអនុម័តលើជំនួយការដើម្បីឱ្យពួកគេអាចចូលរួមក្នុងដំណើរការនីតិវិធី CARE បាន។

អ្នកឆ្លើយតបអាចជ្រើសរើសមិនយកជំនួយការបាន។

## តើអាចផ្លាស់ប្តូរជំនួយការក្នុងអំឡុងពេលនៃដំណើរការនីតិវិធី CARE បានទេ?

អ្នកឆ្លើយតបអាចជ្រើសរើសជំនួយការថ្មីនៅពេលណាក៏បានដែរ។

តុលាការអាចសម្រេចដកជំនួយការចេញបានប្រសិនបើមានទំនាស់ផលប្រយោជន៍ មានន័យថាមានជម្លោះដែលមិនអាចគ្រប់គ្រងបានដើម្បីចៀសវាងការបង្កគ្រោះថ្នាក់ដល់អ្នកឆ្លើយតប។ ប្រសិនបើជម្លោះនោះមិនអាចគ្រប់គ្រងបានទេ តុលាការត្រូវតែដកជំនួយការចេញ។

## តើជំនួយការអាចចូលរួមធ្វើអ្វីបានខ្លះ?

អ្នកឆ្លើយតបអាចសុំឱ្យជំនួយការចូលរួមក្នុងកិច្ចប្រជុំ ដំណើរការនីតិវិធីតុលាការ អង្គសវនាការពីស្ថានភាពណាមួយ ឬការទំនាក់ទំនងផ្សេងៗ។ ចំណុចទាំងអស់នេះអាចទាក់ទងនឹងកិច្ចការណាមួយខាងក្រោម៖

- ការវាយតម្លៃសុខភាពផ្លូវចិត្ត/ផ្លូវអារម្មណ៍។
- ការអភិវឌ្ឍន៍កិច្ចព្រមព្រៀង CARE ឬគម្រោង CARE។
- ការបង្កើតការណែនាំអំពីចិត្តសាស្ត្រជាមុន (PAD)។
- ការអភិវឌ្ឍន៍ផែនបញ្ចប់ពីគម្រោង។

## តើកត្តាអ្វីខ្លះដែលត្រូវយកមកពិចារណានៅពេលបំពេញតួនាទីជាជំនួយការ?

- ជំនួយការនឹងគាំទ្រឆន្ទៈ និងចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតបម្នាក់ៗឱ្យអស់ពីសមត្ថភាព តាមដែលអាចធ្វើទៅបាន។
- ជំនួយការនឹងមិនធ្វើសកម្មភាពដោយឯករាជ្យក្នុងនាមអ្នកឆ្លើយតបឡើយ។
- ជំនួយការនឹងគោរពតម្លៃ ជំនឿ និងចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតបជានិច្ច។
- ជំនួយការនឹងប្រព្រឹត្តដោយស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងដោយស្មោះអស់ពីចិត្ត។
- ជំនួយការគួរតែជៀសវាង កាត់បន្ថយ និងគ្រប់គ្រងទៅលើជម្លោះផលប្រយោជន៍ឱ្យអស់ពីលទ្ធភាពខ្លួន។ បើមានជម្លោះណាមួយ ត្រូវតែពិភាក្សាជាមួយតុលាការ អ្នកឆ្លើយតប និងមេធាវីរបស់អ្នកឆ្លើយតប។
- ជំនួយការនឹងគោរពតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលការពារមនុស្សពីការក្លែងបន្លំ ការរំលោភបំពាន ការធ្វេសប្រហែស ការបង្ខិតបង្ខំ ឬការធ្វើបាបផ្សេងៗ។

លុះត្រាតែមានការអនុញ្ញាតពីអ្នកឆ្លើយតបដែលមានសមត្ថភាពក្នុងការធ្វើការអនុញ្ញាតនោះ ជំនួយការនឹងមិន៖

- ធ្វើការសម្រេចចិត្តសម្រាប់ ឬជំនួសឱ្យ អ្នកឆ្លើយតបទេ លើកលែងតែក្នុងករណីចាំបាច់ ដើម្បីការពារការបង្កគ្រោះថ្នាក់ ឬរបួសរាងកាយដែលនឹងអាចកើតមានឡើង។
- ចុះហត្ថលេខាលើឯកសារក្នុងនាមជាអ្នកឆ្លើយតប។

DHCS
CALIFORNIA DEPARTMENT OF HEALTH CARE SERVICES

## តើជំនួយការអាចទទួលបានការបណ្តុះបណ្តាលអ្វីខ្លះ?

ជំនួយការនឹងមានសិទ្ធិចូលរៀនវគ្គបណ្តុះបណ្តាល ដើម្បីបំពេញតួនាទីខ្លួន។ ការបណ្តុះបណ្តាលទាំងអស់នេះគឺផ្តល់ឱ្យអ្នកពាក់ព័ន្ធទាំងអស់របស់គម្រោង CARE ព្រមទាំងជំនួយការផងដែរ។ ការបណ្តុះបណ្តាលទាំងអស់នេះនឹងធ្វើឱ្យការយល់ដឹងរបស់ពួកគេកាន់តែស៊ីជម្រៅបន្ថែមទៀតពីដំណើរការនីតិវិធី CARE។ ពួកគេស្វែងយល់ពីគំនិតដែលពាក់ព័ន្ធ ដើម្បីធ្វើឱ្យដំណើរការនីតិវិធី CARE កាន់តែរឹងមាំដល់អ្នកចូលរួមទាំងអស់។ ប្រធានបទបណ្តុះបណ្តាលរួមមាន៖

- ទិដ្ឋភាពទូទៅនៃដំណើរការនីតិវិធី CARE សម្រាប់ជំនួយការគ្រប់រូប
- ទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀង CARE & គម្រោង CARE
- តួនាទីរបស់ជំនួយការនៅក្នុងច្បាប់ CARE
- ការសម្រេចចិត្តដោយមានការជួយគាំទ្រសម្រាប់ជំនួយការស្ម័គ្រចិត្តគ្រប់រូប
- ការរក្សាអព្យាក្រឹតភាពក្នុងនាមជាជំនួយការស្ម័គ្រចិត្ត
- ការណែនាំអំពីចិត្តសាស្រ្តជាមុន
- ការបណ្តុះបណ្តាលនានា អំពី ជំងឺខ្លាចសង្គម ដល់ជំនួយការ៖ ផ្នែក 1, ផ្នែក 2, និង ផ្នែក 3
- ការបណ្តុះបណ្តាលនានា អំពីការថែទាំរបួសតាមបទដ្ឋានបច្ចេកទេស (TIC) ដល់ជំនួយការ៖ ផ្នែក 1, ផ្នែក 2, និង ផ្នែក 3
- លំនៅឋាន សេវាកម្ម និងជំនួយផ្សេងៗដែលអាចរកបានតាមរយៈច្បាប់ CARE៖ ការបណ្តុះបណ្តាលដល់ជំនួយការ

## ធនធាននានាបន្ថែម

ពិនិត្យមើលធនធានច្បាប់ CARE បន្ថែម៖

- សេចក្តីសង្ខេប អំពី ច្បាប់ CARE
- លំហូរដំណើរការនីតិវិធី CARE ឆ្ពោះទៅកាន់ការព្យាបាល លំនៅឋាន និងការជួយគាំទ្រ
- ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

## លក្ខន្តិកៈភាសា &សេចក្តីយោង

**"ជំនួយការ"** មានន័យថាជាមនុស្សពេញវ័យ ដែលត្រូវបានចាត់តាំងស្របតាមជំពូកទី 4 (ចាប់ផ្តើមជាមួយ ក្រម W&I § 5980)។ ជំនួយការជួយបុគ្គលដែលជាកម្មវត្ថុនៃការដាក់ញត្តិ។ ការជួយនេះរួមមានការជួយគាំទ្របុគ្គលនោះឱ្យយល់ ប្រតិបត្តិ ទំនាក់ទំនង អនុវត្ត ឬធ្វើសកម្មភាពលើការសម្រេចចិត្តក្នុងជីវិតរបស់ពួកគេផ្ទាល់ក្នុងអំឡុងពេលនៃដំណើរការនីតិវិធី CARE រួមមាន កិច្ចព្រមព្រៀង CARE គម្រោង CARE និងការបង្កើតផែនការបញ្ចប់ពីគម្រោង។ **ជំនួយការ**មិនត្រូវធ្វើសកម្មភាពណាមួយដោយឯករាជ្យឡើយ។ (ក្រម W&I § 5981)

សូមមើល ក្រម W&I ផ្នែក 5972 យោងទៅលើតួនាទីរបស់ជំនួយការនៅក្នុងច្បាប់ ជំនួយសហគមន៍ ការស្តារឡើងវិញ និងការផ្តល់សិទ្ធិអំណាច (CARE)។ ចំណុចនេះរួមមានតួនាទីរបស់ជំនួយការក្នុងការអភិវឌ្ឍន៍កិច្ចព្រមព្រៀង CARE (ក្រម W&I § 5977(c)(2)) និងគម្រោង CARE (ក្រម W&I § 5977.1(c)); ទំនួលខុសត្រូវរបស់ជំនួយការ (ក្រម W&I § 5981(b)); កិច្ចការងារដែលជំនួយការមិនអាចធ្វើបាន (ក្រម W&I § 5981 (c)); សេចក្តីយោងទៅលើការដកជំនួយការចេញ (ក្រម W&I § 5981 (b)(4)); បទប្បញ្ញត្តិដែលជំនួយការត្រូវបានចងភ្ជាប់ដោយកាតព្វកិច្ច និងការហាមឃាត់ដែលមានស្រាប់ ដែលការពារជនពិការ និងមនុស្សចាស់ពីការក្លែងបន្លំ ការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ការបង្ខិតបង្ខំ ឬការធ្វើបាបផ្សេងៗ (ក្រម W&I § 5981(d)); និងបទប្បញ្ញត្តិដែលថា ជំនួយការមិនត្រូវបានកោះហៅ ឬហៅឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងអ្នកឆ្លើយតប (ក្រម W&I§ 5981 (e))។

DHCS
CALIFORNIA DEPARTMENT OF
HEALTH CARE SERVICES